# **កម្មវិធី STARTING OUT STRONG របស់ CALWORKs**

## **អ្នកអាចមានលក្ខណៈសម្បត្តិចូលរួមក្នុងកម្មវិធី STARTING OUT STRONG របស់ CALWORKs**

### **អំពីកម្មវិធី Starting Out Strong របស់ CALWORKS**

- កម្មវិធី Starting Out Strong របស់ CalWORKs គឺជាកម្មវិធីស្ម័គ្រចិត្ត ដែលភ្ជាប់អ្នកជាមួយនឹងគិលានុបដ្ឋាក ឬអ្នកវិជ្ជាជីវៈដែលទទួលបានការបណ្តុះបណ្តាល ដែលនឹងជួបអ្នក នៅទីតាំងមួយ ដែលអ្នកជ្រើសរើសនៅក្នុងសហគមន៍ នៅការិយាល័យរបស់យើង ឬនៅគេហដ្ឋានរបស់អ្នក។

- កម្មវិធីផ្តល់ជំនួយចិញ្ចឹមកូន ការតស៊ូមតិ និងសកម្មភាពផ្សេងៗ ដើម្បីជួយដល់លទ្ធភាពទទួលបាននូវការថែទាំមុន និងក្រោយពេលសម្រាលកូន សេវាសុខភាព និងសង្គមផ្សេងៗ ការអប់រំពីការចិញ្ចឹមកូន ជំនួយចិញ្ចឹមកូន។

- គ្រួសាររបស់អ្នកអាចមានសិទ្ធិទទួលបានសេវាគាំពារទាំងនេះ សម្រាប់រយៈពេលរហូតដល់ម្ភៃបួនខែ ឬរហូតដល់កូនអ្នកដល់អាយុពីរខួប គឺពេលណាក៏ដោយ ដែលកើតក្រោយគេ។

### **លក្ខណៈសម្បត្តិចុះឈ្មោះក្នុងកម្មវិធី**

- ជាសមាជិកនៅក្នុងផ្នែកជំនួយ CalWORKs ឬឪពុក/ម្តាយ/សាច់ញាតិដែលផ្តល់ការថែទាំ សម្រាប់តែករណីកូនមួយប៉ុណ្ណោះ និង
- បច្ចុប្បន្នមានផ្ទៃពោះ ឬឪពុក/ម្តាយ/អ្នកថែទាំកុមារអាយុតិចជាង 36 ខែ ពេលចុះឈ្មោះក្នុងកម្មវិធី Starting Out Strong របស់ CalWORKs។

### **ជំនួយពីកម្មវិធី**

- ពីការចូលរួមក្នុងកម្មវិធី ដូចជា៖
  - សុខភាពរបស់អ្នក និងកូនរបស់អ្នកកាន់តែល្អប្រសើរឡើង
  - ជំនាញ និងគំនិតចិញ្ចឹមថែទាំកូនថ្មីៗ
  - កាត់បន្ថយកម្រិតស្ត្រេស
  - ការគាំពារការរីកលូតលាស់របស់កូនអ្នក
  - ការបញ្ជូនណែនាំ និងធនធានសម្រាប់អ្នក និងកូនរបស់អ្នក និង
  - ឱកាសសម្រាប់កូនអ្នកចុះឈ្មោះ ដើម្បីទទួលសេវាថែទាំកុមារគុណភាពខ្ពស់ ក្រុមលេងសប្បាយ ឬសកម្មភាពចម្រើនដទៃ ដើម្បីឲ្យកូនរបស់អ្នកមានការចាប់ផ្តើមជីវិតល្អប្រសើរបំផុត។
- បុគ្គលិកចុះតាមផ្ទះ នឹងផ្តល់ការណែនាំ ការបង្រៀន និងការភ្ជាប់ទៅនឹងធនធាន ដែលជួយលើកកម្ពស់ការអប់រំ ទស្សនៈវិស័យសង្គម សេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់គ្រួសាររបស់អ្នក។

*មូលនិធិសម្រាប់កម្មវិធីនេះ ទទួលបានពីគំនិតផ្តួចផ្តើម Home Visiting នៃកម្មវិធី CalWORKs របស់ក្រសួងសេវាសង្គមកិច្ចរដ្ឋ California។*

ដើម្បីស្ម័គ្រចិត្តចូលរួមក្នុងកម្មវិធីនេះ សូមចុះហត្ថលេខា កាលបរិច្ឆេទ និងបញ្ជូនទម្រង់នេះ ត្រឡប់មកឲ្យបុគ្គលិករបស់ទីភ្នាក់ការសេវាសង្គមកិច្ច (Social Services Agency (SSA)) វិញ។

**<u>សំណើសុំចូលរួមក្នុងកម្មវិធី STARTING OUT STRONG</u>**

- ☐ ចង់ចូលរួមក្នុងកម្មវិធី Starting Out Strong របស់ CalWORKs ហើយខ្ញុំយល់ដឹងថា ខ្ញុំអាចជ្រើសរើសកន្លែង ដែលយើងជួបគ្នា និងបញ្ឈប់ការផ្តល់សេវារបស់កម្មវិធីដោយស្ម័គ្រចិត្ត នៅពេលណាក៏បាន។
  **ខ្ញុំ៖**
  **... មានផ្ទៃពោះ ... គឺជាឪពុក/ម្តាយ/អាណាព្យាបាលកុមារអាយុតិចជាង 36 ខែ**

- ☐ ខ្ញុំមិនចង់ចូលរួមក្នុងកម្មវិធី Starting Out Strong នៅពេលនេះទេ ប៉ុន្តែ ខ្ញុំយល់ដឹងថា ខ្ញុំអាចស្ម័គ្រចិត្តចូលរួមក្នុងកម្មវិធីនេះបាន នាពេលអនាគត ដោយជូនដំណឹងបុគ្គលិក SSA ដែលនឹងកំណត់ថាតើ ខ្ញុំនៅតែមានសិទ្ធិចូលរួម ឬយ៉ាងណា។

មូលហេតុនៃការបដិសេធចំពោះសេវាចុះតាមផ្ទះ៖

- ☐ បច្ចុប្បន្នកំពុងទទួលសេវាចុះតាមផ្ទះ។
- ☐ មិនយល់ថា កម្មវិធីនេះនឹងផ្តល់អត្ថប្រយោជន៍ឡើយ។
- ☐ មិនចាប់អារម្មណ៍ចង់ទទួលសេវាចុះតាមផ្ទះឡើយ។
- ☐ ផ្សេងទៀត៖ ____________________

**ដោយចុះហត្ថលេខាលើទម្រង់នេះ ខ្ញុំយល់ដឹងពីចំណុច ដូចខាងក្រោម៖**

- ព័ត៌មាន ដែលខ្ញុំបានផ្តល់នេះ នឹងត្រូវចែករំលែកជាមួយនឹង Alameda County Public Health Department ដូច្នេះ គេអាចទាក់ទងខ្ញុំ និងកំណត់ពេលវេលា សម្រាប់ចាប់ផ្តើមចុះមកទីតាំងដែលខ្ញុំជ្រើសរើស។
- ខ្ញុំអាចបញ្ឈប់ការចុះតាមផ្ទះ នៅពេលណាក៏បាន។ និង
- ការចូលរួមក្នុងកម្មវិធីនេះ នឹងមិនប៉ះពាល់ដល់សិទ្ធិទទួលបានជំនួយ ការគាំពារ ឬសេវាដទៃទៀតនៃកម្មវិធី CalWORKs ឡើយ រាប់បញ្ចូលទាំង ខលើកលែងនៃជំនួយដើម្បីឲ្យធ្វើការ ផងដែរ។

| | |
|---|---|
| ឈ្មោះសំណុំរឿង | លេខសំណុំរឿង |
| ឈ្មោះឪពុក/ម្តាយ ឬសាច់ញាតិដែលផ្តល់ការថែទាំ | ទូរស័ព្ទ |
| ហត្ថលេខាឪពុក/ម្តាយ ឬសាច់ញាតិដែលផ្តល់ការថែទាំ | កាលបរិច្ឆេទ |